# សេចក្តីថ្លែងការណ៍រួម

## ការលើកកម្ពស់សិទ្ធិរបស់ស្ត្រីនៅកន្លែងការងារពិតជាមានសារៈសំខាន់បំផុត

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១

យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម មានការខកចិត្តជាខ្លាំងនៅពេលដែលបានអានសេចក្តីរាយការណ៍ទាក់ទងនឹងមន្ត្រីនគរបាលជាស្ត្រីម្នាក់ បានប្រឈមនឹងវិធានការវិន័យដោយសារការបង្ហោះរូបភាពនៃការបំបៅដោះកូនក្នុងសំលៀកបំពាក់ឯកសណ្ឋាននគរបាលនៅលើទំព័រគណនីហ្វេសប៊ុកផ្ទាល់ខ្លួនរបស់គាត់។ រឿងដែលធ្វើឱ្យកាន់តែខកចិត្តទៅទៀតនោះគឺករណីនេះបានកើតឡើងតែមួយថ្ងៃប៉ុណ្ណោះ បន្ទាប់ពីទិវានារីអន្តរជាតិ ដែលនេះបង្ហាញឱ្យឃើញថែមទៀតថា សិទ្ធិស្ត្រីនៅតែជាបញ្ហាប្រឈមនៅប្រទេសកម្ពុជា។

ស្ត្រីមិនគួរត្រូវបានបង្ខំឱ្យជ្រើសរើសរវាងការងារ និងការមើលថែទាំកូននោះទេ។ ប្រការដែលស្ត្រីជាម្តាយហើយដែលទៅធ្វើការនឹងត្រូវស្តីបន្ទោស បើស្ត្រីនោះធ្វើទាំងការងារនិងភារកិច្ចមើលថែទាំកូន ដូចជាករណីនេះជាឧទាហរណ៍ស្រាប់ ដែលនេះបង្ហាញឲ្យឃើញថារដ្ឋាភិបាលខកខានក្នុងការការពារសិទ្ធិស្ត្រីនៅកន្លែងធ្វើការ ទោះបីជាប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ស៊ី ដ) ដែលការពារសិទ្ធិធ្វើការងារដោយមិនមានការរើសអើង។

នៅកម្ពុជា ថ្វីបើកម្លាំងពលកម្មស្ត្រីមានចំនួនប្រហាក់ប្រហែលនឹងបុរសក្តី ក៏ចំនួនស្ត្រីនៅក្នុងតំណែងជាអ្នកដឹកនាំនៅមានកម្រិតនៅឡើយ។ ផ្នត់គំនិតមិនជឿនលឿន បរវេណី និងវប្បធម៌ដែលបានចាក់ឫសកប់យ៉ាងជ្រៅនេះ បន្តកើតមានដែលជាតថភាពមួយនៅតែជាក្តីបារម្ភ។ ម្យ៉ាងទៀត ប្រការដែលស្ថាប័នការងារជាច្រើនពុំបានផ្តល់ហេដ្ឋារចនាសម្ព័ន្ធឬបរិក្ខារមើលថែទាំទារកគ្រប់គ្រាន់សម្រាប់បុគ្គលិក ឬកម្មករនិយោជិតជាម្តាយ ឬឆ្លើយតបនឹងតម្រូវការចាំបាច់ដល់ពួកគាត់ គឺជាឧបសគ្គដ៏ធំមួយក្នុងចំណោមឧបសគ្គជាច្រើនទៀត ដែលរារាំងស្ត្រីក្នុងការឡើងទៅកាន់តំណែងជាថ្នាក់ដឹកនាំ។ ដើម្បីឱ្យស្ត្រីទទួលបានសិទ្ធិនៅកន្លែងធ្វើការ ជាការសំខាន់បំផុតគឺត្រូវផ្តល់ហេដ្ឋារចនាសម្ព័ន្ធនិងបរិក្ខារមើលថែទារក ទារកដ្ឋាននិងពេលវេលាសម្រាកក្នុងការបំបៅកូនដោយទទួលបានប្រាក់ឈ្នួលដល់បុគ្គលិក ឬកម្មករនិយោជិត ព្រមទាំងបង្កភាពងាយស្រួលដល់ពួកគេក្នុងការបន្តអាជីពការងាររបស់ខ្លួន។

នោះគឺជារឿងគួរឱ្យអាម៉ាសចំពោះការតម្រូវឱ្យមន្ត្រីនគរបាលនោះត្រូវសុំទោស ក្រោមហេតុផលថាបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាពនិងស្ត្រីខ្មែរ ហើយតម្រូវឲ្យនាងចុះកិច្ចសន្យាមិនបន្តអកប្បកិរិយាបែបនេះទៅទៀត។ ក្រោយមក បន្ទាប់ពីការមានការរិះគន់ពីសាធារណៈជន មន្ត្រីនគរបាលជាថ្នាក់ដឹកនាំនោះបានចេញមុខបកស្រាយថា ដោយយោងលើហេតុផលថាអ្នកស្រីនគរបាលរូបនោះ ពុំបានសុំការអនុញ្ញាតជាមុនក្នុងការបង្ហោះរូបភាពនៃការបំបៅដោះកូននៅលើទំព័រហ្វេសប៊ុក ដែលការពន្យល់នេះបង្កើនការព្រួយបារម្ភថែមទៀតអំពីសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិសេរីភាពក្នុងការសម្តែងអំពីអារម្មណ៍ផ្ទាល់ខ្លួនគឺជាសិទ្ធិដែលមានការទទួលស្គាល់ជាអន្តរជាតិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ពុំមែនជាបុព្វសិទ្ធិពិសេស ហើយក៏ពុំមែន

ការប្រទានដោយការអនុគ្រោះនោះដែរ សិទ្ធិនេះត្រូវបានរឹតត្បិតតែក្នុងលក្ខខណ្ឌចាំបាច់បំផុតតែប៉ុណ្ណោះ ហើយគ្មានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះឆ្លើយតបករណីនេះនោះទេ។

ចំពោះករណីខាងលើនេះ យើងខ្ញុំស្នើដល់មន្ត្រីនគរបាលជាថ្នាក់ដឹកនាំស្ត្រីនគរបាលរូបនោះ គប្បីចេញមុខសុំអភ័យទោសជាសាធារណៈចំពោះឥរិយាបថផ្ដាំផ្ញើងក្នុងការដោះស្រាយករណីនេះ និងចំពោះការធ្វើឱ្យប៉ះពាល់កិត្តិយសនិងសេចក្ដីថ្លៃថ្នូរបស់មន្ត្រីក្រោមឱវាទរបស់ខ្លួន។ ម្យ៉ាងវិញទៀត អគ្គស្នងការនគរបាលជាតិគួរមានវិធានការឱ្យកែតម្រូវដើម្បីធានាថាករណីនេះនឹងពុំកើតឡើងសារជាថ្មី និងដើម្បីធានាឱ្យមានសមភាពយេនឌ័រនៅកន្លែងការងារផងដែរ។

យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាមានវិធានការដូចខាងក្រោម ៖

- ចាត់វិធានការសមស្របដើម្បីធានាថាឪពុកម្ដាយគ្រប់រូប ដែលបំពេញការងារទទួលបានការគាំទ្រនៅក្នុងកន្លែងការងារ ហើយស្ថាប័នការងារត្រូវផ្ដល់បរិក្ខារ និងទីកន្លែងមើលថែទាំទារកដែលជាតម្រូវការចាំបាច់ខ្លាំងសម្រាប់បុគ្គលិកឬកម្មករនិយោជិតជាម្ដាយ
- ចាត់វិធានការដើម្បីធានាថាសិទ្ធិរបស់ស្ត្រីនៅកន្លែងការងារត្រូវបានគោរពនិងលើកកម្ពស់
- អនុវត្តអនុសាសន៍ដែលប្រទេសកម្ពុជាបានទទួលយកតាមរយៈយន្តការនៃការពិនិត្យជាសកលតាមកាលកំណត់ (យូភីអ) ក្នុងឆ្នាំ២០១៩ ក្នុងនោះមានដូចជាបង្កើនកិច្ចប្រឹងប្រែងឱ្យបានខ្លាំងក្នុងការលុបបំបាត់ការរើសអើងលើស្ត្រីភេទជាដើម
- អនុម័តកិច្ចគាំពារពាក់ព័ន្ធនឹងអំឡុងពេលមាតុភាព ដែលអនុលោមតាមបញ្ញត្តិក្នុងអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិលេខ ១៨៣ និង
- បញ្ឈប់ការរឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិ៕

---- ចប់ -----

សេចក្ដីថ្លែងការណ៍រួមនេះគាំទ្រដោយ ៖

1. សកម្មភាពដើម្បីអភិវឌ្ឍន៍
2. អង្គការអាក់សិនអេតកម្ពុជា
3. វិទ្យាស្ថានតស៊ូមតិ និង គោលនយោបាយ
4. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់
5. សមាគមអ្នកបម្រើការងារតាមផ្ទះ
6. សមាគមគាំពារស្ត្រីងាយរងគ្រោះ
7. សហជីពកម្មករចំណីអាហារនិងសេវាកម្មកម្ពុជា
8. សហភាពការងារកម្ពុជា
9. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា
10. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា

11 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
12 មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
13 អង្គការជនពិការកម្ពុជា
14 អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍
15 សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
16 អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិនុស្ស លីកាដូ
17 អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
18 បណ្តាញយុវជនកម្ពុជា
19 មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស
20 សហគមន៍ ដីខក្រោមក្រុម១៧៥គ្រួសារ
21 សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា
22 មជ្ឈមណ្ឌលអប់ច្បាប់សម្រាប់សហគមន៍
23 ជំនួយរបស់វិហារដាណឺម៉ាក
24 អង្គការសមធម៌កម្ពុជា
25 អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
26 បណ្តាញយេនឌ័រនិងអភិវឌ្ឍន៍កម្ពុជា
27 សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
28 អង្គការក្លាហាន
29 ជំនួយផ្លូវច្បាប់ដល់ កុមារ និងស្ត្រី
30 អង្គការម្លប់បៃតង
31 គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ
32 សមាគមថែទាំសុខភាពគ្រួសារកម្ពុជា
33 អង្គការសមាគមជាងឆ្នោត
34 អង្គការសីលការ
35 គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញា លុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី
36 អង្គការសម្ព័នដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម
37 អង្គការតម្លាភាពកម្ពុជា
38 អង្គការនារីដើម្បីសន្តិភាព
39 អង្គការកម្មវិធីអភិវឌ្ឍធនធានយុវជន